ខ្ញុំទទួលយក

# សហគមន៍ឥន្ទធនូកម្ពុជា៖ ដំណើរឆ្ពោះទៅរកសមភាពអាពាហ៍ពិពាហ៍នៅកម្ពុជាពោរពេញដោយក្ដីសង្ឃឹម

**២៨ មករា ២០២៥**



មានមនុស្សជាច្រើនឆ្ងល់ថា តើពេលណាទើបប្រទេសកម្ពុជាមានច្បាប់អនុញ្ញាតិឱ្យគូស្រករភេទដូចគ្នាអាចរៀបការស្របតាមច្បាប់បាន? ដោយសារ ការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា មានការកើនឡើងជុំវិញពិភពលោក ហើយថ្មីៗនេះប្រទេសថៃបានអនុម័តច្បាប់ទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នាផងដែរ។ តើការណ៍នេះអាចជួយជំរុញកម្ពុជាបែបណា? ដើមចមនៃចម្ងល់នេះ គឺដោយសារតែប្រព័ន្ធផ្សព្វផ្សាយបានចែកចាយយ៉ាងផុសផុលអំពីការ វិវត្តន៍ជាវិជ្ជមានរបស់ប្រទេសថៃ ដោយរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាបានបោះឆ្នោតសម្រេចជាបន្តបន្ទាប់ចាប់ពីខែមីនា រហូតដល់ខែមិថុនា ឆ្នាំ២០២៤ ដើម្បីអនុម័តលើសេចក្តីព្រាងច្បាប់សមភាពអាពាហ៍ពិពាហ៍។ បន្ទាប់មកច្បាប់សមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា ត្រូវបានឡាយព្រះហស្តលេខាអនុម័តដោយព្រះមហាក្សត្រនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤ ដែលធ្វើឱ្យប្រទេសថៃក្លាយជាប្រទេសដំបូងគេ នៅតំបន់អាស៊ីអាគ្នេយ៍ ដែលទទួលស្គាល់ការរៀបការស្របច្បាប់សម្រាប់គូស្រករភេទដូចគ្នា។ បន្ទាប់ពីច្បាប់ចូលជាធរមាន នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ គូស្រករភេទដូចគ្នានៅក្នុងប្រទេសថៃ អាចចុះសំបុត្រអាពាហ៍ពិពាហ៍បាន ដែលធ្វើឱ្យក្តីស្រឡាញ់ និងអាពាហ៍ពិពាហ៍ស្មើភាពគ្នាត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកគាំទ្ររួមមាន ក្រុមគ្រួសារ មិត្តភក្តិ សាធារណជន ក៏ដូចជាមន្ត្រីរាជរដ្ឋាភិបាលមួយចំនួននៅកម្ពុជា ក៏បាន និងកំពុងចូលរួមអបអរសាទរជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកគាំទ្រនៅប្រទេសថៃ ដែលជាប្រទេសជិតខាងយើងចំពោះជ័យជម្នះនេះផងដែរ។

ប្រសិនបើយើងក្រឡេកមើលទៅប្រទេសថៃ និងកម្ពុជា មានភាពប្រហាក់ប្រហែលគ្នាច្រើនដូចជា វប្បធម៌ ប្រពៃណី សាសនា ប្រព័ន្ធច្បាប់ និងការគ្រប់គ្រងរដ្ឋបាលជាដើម។ ជំនួសឱ្យការឆ្លើយសំនួរខាងលើ យើងសូមបង្វែរចំណាប់អារម្មណ៍ប្រិយមិត្តមកមើលបរិបទ និងស្ថានភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាវិញ ហើយឆ្លុះបញ្ចាំងទាំងអស់គ្នា ថាតើកម្ពុជាអាចនឹងអាចឈានឆ្ពោះទៅសម្រេចគោលដៅនៃសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នាដែរ ឬទេ?

ប្រជាជនខ្មែរមានភាពចម្រុះ ទាំងនៅទីក្រុង និងជនបទ ដែលភាគច្រើនប្រតិបត្តិនូវគុណតម្លៃវប្បធម៌ និងសង្គមដ៏ល្អគឺការគោរព ស្រឡាញ់ រាប់អាន ជួយគ្នា និងសាមគ្គី ប្រកបដោយភាពសុខដុមជាពិសេសគឺការឱ្យតម្លៃ និងការពារគ្រួសារ។

ទឹកចិត្តរបស់ប្រជាជន និងបរិយាកាសនៅក្នុងសហគមន៍ និងសង្គមខ្មែរមានការអត់ឱន និងអធ្យាស្រ័យចំពោះគ្នា។ ការយោគយល់នេះ ក៏មានចំពោះអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ ដោយយើងព្យាយាមបើកចិត្តស្វែងយល់ ទទួលស្គាល់ រាប់អាន ហើយអាចធ្វើការ និងរួមរស់ជាមួយគ្នាបានដ៏សុខសាន្ត។ ក្នុងរយៈពេលជាង២០ឆ្នាំកន្លងទៅ ស្ថានភាពនេះកាន់តែមានភាពប្រសើរឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈកិច្ចប្រឹងប្រែងក្នុងការពង្រឹងភាពម្ចាស់ការ សេចក្តីក្លាហាន ទំនុកចិត្ត សមត្ថភាព ការកសាងមិត្តភាព និងបណ្តាញសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេស។ យើងក៏បានធ្វើការសហការប្រកបដោយបុរេសកម្ម រវាងសហគមន៍អ្នកស្រឡាញ់ភេដូចគ្នា និងអ្នកគាំទ្រនៃសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ អាជ្ញាធរមូលដ្ឋាន ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ភ្នាក់ងារអភិវឌ្ឍន៍ និងបណ្តាញសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេស ថ្នាក់តំបន់ និងអន្តរជាតិផងដែរ។ កិច្ចសហការរបស់យើង គឺដើម្បីចូលរួមអប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹង ពិភាក្សា និងគាំទ្រនូវការគោរព ក៏ដូចជាការពារសេចក្តីថ្លៃថ្នូរ និងភាពចម្រុះរាប់ទាំងភេទកំណើត អត្តសញ្ញាណយេនឌ័រ ដែលកំណត់ដោយបុគ្គលផ្ទាល់ខ្លួន និងនិន្នាការភេទ ឬសេចក្តីស្រឡាញ់របស់មនុស្សម្នាក់ៗ។

ប្រជាពលរដ្ឋខ្មែរដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ទទួលបានការយកចិត្តទុកដាក់ខ្ពស់ និងគាំទ្រពីសំណាក់ថ្នាក់ដឹកនាំកំពូលៗរបស់កម្ពុជា។ ត្វយ៉ាង នៅឆ្នាំ២០០៤ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «ព្រះបរមរតនកោដ្ឋ»** ទ្រង់បានមានព្រះបន្ទូលគាំទ្រនូវការរៀបការរវាងប្រជាពលរដ្ឋខ្មែរ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។ ប្រាំពីរឆ្នាំក្រោយមក នាឱកាសអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០១២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានព្រឹទ្ធសភា** ក៏បានមានប្រសាសន៍អំពាវនាវដល់សាធារណជនខ្មែរនៅទូទាំងប្រទេស កុំឱ្យមានភាពរើសអើង ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ដែលកើតមកមានធម្មជាតិបែបនេះ។ សេចក្តីអំពាវនាវនេះ រាប់បញ្ចូលទាំងការជំរុញលើកទឹកចិត្តដល់មន្ត្រីរដ្ឋាភិបាលគ្រប់កម្រិត ត្រូវបានលើកឡើងជាបន្តបន្ទាប់នៅក្នុងវេទិកាសំខាន់ៗផងដែរ។ អ្វីដែលពិសេសនោះគឺ នៅឆ្នាំ២០១៨ នាឱកាសកម្មវិធីអបអរខួប១០ឆ្នាំរបស់សហគមន៍ឥន្ទធនូកម្ពុជា **សម្តេចតេជោ** ក៏បានបញ្ជាក់តាមរយៈ **ឯកឧត្តម កែវ រ៉េមី ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**ថា កម្ពុជានឹងធ្វើជាប្រទេសឈានមុខគេក្នុងតំបន់ចំពោះការមិនរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា។ ការគាំទ្រដ៏មានអត្ថន័យ



និងតម្លៃមិនអាចកាត់ថ្លៃ ទាំងនេះ ត្រូវបានចងក្រងជាប្រវត្តិសាស្រ្ត ដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងក្រុមគ្រួសាររបស់យើងចងចាំទុកនៅក្នុងចិត្តជានិរន្ត ហើយបន្តរំឭកប្រាប់គ្នាពីជំនាន់មួយទៅជំនាន់មួយ។

នៅក្នុងក្របខណ្ឌគោលនយោបាយ ផែនការ និងកម្មវិធីជាតិ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាក់ព័ន្ធ ដូចជាក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាជាក្រុមងាយរងគ្រោះ និងរងហានិភ័យនៃការការពារពីអំពើហិង្សាផ្អែកលើយេនឌ័រ។ ជាក់ស្តែង នៅក្នុងគោលនយោបាយនារីរតនៈទី៦ ផែនការសកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រីទី៣ ហើយឈានដល់ទី៤ និងកម្មវិធីសិក្សាបំនិនជីវិតផ្នែកអប់រំរឿងផ្លូវភេទគ្រប់ជ្រុងជ្រោយ ដោយបានបញ្ចូលនូវគោលគំនិតនៃនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ លក្ខណៈភេទ និងសមភាពយេនឌ័រ។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានប្តេជ្ញាចិត្តបន្តទៀតនៅឆ្នាំ២០១៩ តាមរយៈយន្តការ នៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR)ជុំទី៣ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ កម្ពុជាបានទទួលយកអនុសាសន៍ចំនួនប្រាំបួន អំពីការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាលើអាទិភាពចំនួនបី គឺសមភាពច្បាប់អាពាហ៍ពិពាហ៍ ការទទួលស្គាល់អត្តសញ្ញាណយេនឌ័របុគ្គល និងកិច្ចគាំពារពីការរើសអើង។

បើក្រឡេកមើលការវិវឌ្ឍថ្មីៗ គឺនៅខែមិថុនា ឆ្នាំ២០២៤ កម្ពុជាបានចូលរួមគាំទ្រសេចក្តីថ្លែងការណ៍រួមស្តីពីការមិនដាក់ទោសទណ្ឌជាសកលលើអ្នកស្រឡាញ់ភេទដូចគ្នាដែលបង្ហាញពីការប្តេជ្ញាចិត្តដ៏សំខាន់ក្នុងការការពារ និងលើកកម្ពស់សមភាពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងការមិនរើសអើង។ ថ្មីៗនេះក្នុង **ខែតុលា ឆ្នាំ២០២៤ កម្ពុជាបានទទួលយកជាផ្លូវការនូវអនុសាសន៍ទាំង១២ ស្តីពីការបន្តការលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ក្នុង**នៅរបាយការណ៍ពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR)ជុំទី៤ ដែលក្នុងនោះមាន**អនុសាសន៍ចំនួន៧ ដើម្បីបន្តវឌ្ឍនភាពឆ្ពោះទៅរកការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា** និងអនុសាសន៍ផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដែលកំណត់ដោយបុគ្គល សម្រាប់អ្នកប្តូរយេនឌ័រ និងបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រចម្រុះហើយបន្តវឌ្ឍនភាពឆ្ពោះទៅរកសមភាពពេញលេញសម្រាប់អ្នកស្រឡាញ់ ភេទដូចគ្នា និងអនុវត្តនូវវិធានការការពារប្រកបដោយប្រសិទ្ធិភាព ពីការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ(SOGIESC)។ ការសម្រេចចិត្តរបស់កម្ពុជាក្នុងការទទួលយកអនុសាសន៍ UPR ជុំទី៤អំពីសមភាពអ្នកស្រឡាញ់ភេទដូចគ្នាបង្ហាញជាជំហានវិជ្ជមានដ៏សំខាន់មួយនៅពេលដែល**កម្ពុជាធ្វើការប្តេជ្ញាចិត្តបន្តឆ្ពោះទៅរកការអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងនេះ និងការជំរុញសិទ្ធិស្មើគ្នាសម្រាប់សហគមន៍អ្នកស្រលាញ់ភេទ ដូចគ្នានៅកម្ពុជា។**




ដំណឹងដ៏វិសេសវិសាលនេះបានជំរុញទឹកចិត្តដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាយើងឱ្យមានសេចក្តីសង្ឃឹម និងភាពជឿជាក់ថា យើងនឹងសម្រេចបាននូវសមភាពពេញលេញសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងពេលឆាប់ៗខាងមុខនេះ ជាពិសេសសមភាពច្បាប់អាពាហ៍ពិពាហ៍ ដែលជាតម្រូវការអាទិភាពរបស់យើង នៅក្នុងសង្គម កម្ពុជាប្រកបដោយបរិយាប័ន្ន និងភាពសុខដុម។ យើងនឹងបន្តធ្វើការរួមគ្នាជាមួយភាគីពាក់ព័ន្ធ តាមរយៈកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការក្នុងដំណើរឆ្ពោះទៅមុខ ដើម្បីបន្តវឌ្ឍនភាពនៃសិទ្ធិស្មើគ្នាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាជាពិសេសសមភាព

ច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា ដើម្បីធានាបាននូវការមិនរើសអើង សមភាពពេញលេញ និងមានបរិយាបន្នសង្គម ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "មិនទុកនរណាម្នាក់ចោល"។

បើក្រឡេកមើលការផ្លាស់ប្តូរនូវផ្នត់គំនិត ការយល់ឃើញ ឥរិយាបថ និងអាកប្បកិរិយា**របស់** **ឪពុកម្តាយ ក្រុមគ្រួសារ** សហគមន៍ **អាជ្ញាធរមូលដ្ឋាន និងមន្ត្រីរាជការ វិញ** គឺកាន់តែមានភាពរីកចម្រើនយ៉ាងទូលំទូលាយចំពោះការទទួលយក និងគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា ទាំងការរៀបការតាមប្រពៃណីនិងតាមច្បាប់។ ការគាំទ្រដ៏ផុសផុលនេះកាន់តែមានសន្ទុះច្រើនឡើងៗ តួយ៉ាងពីរឆ្នាំកន្លងទៅក្នុងឆ្នាំ២០២២ យោងតាមរបាយការណ៍ការស្រាវជ្រាវរបស់ Pew Research Center បានរកឃើញថា ពលរដ្ឋខ្មែរជាមនុស្សពេញវ័យមានរហូតដល់ទៅ៥៧% នៃអ្នកដែលបានចូលរួមផ្តល់បទសម្ភាសប្រមាណ ១៥០០នាក់ បានគាំទ្រច្បាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នារួចទៅហើយ។

ដោយសារតែការវិវត្តន៍ទៅដោយភាពវិជ្ជមានទាំងនេះ ទើបធ្វើឱ្យសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាកាន់តែមានសេចក្តីក្លាហាន និងទំនុកចិត្តក្នុងការចេញមុខជាចំហរ ហើយមានកម្លាំងចិត្ត និងការប្តេជ្ញាចិត្ត ចូលរួមធ្វើការងារយ៉ាងសស្រាក់សស្រាំ។ ការបន្តភាពបុរេសកម្ម គឺមានទាំងការជួយគាំទ្រផ្នែកផ្លូវចិត្ត ចែករំលែកមតិយោបល់ ផ្សព្វផ្សាយព័ត៌មាន ហើយជួយពង្រីកបណ្តាញសហគមន៍ ពង្រឹងសាមគ្គីភាព និងសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីឆាប់សម្រេចបានគោលដៅអាទិភាពមួយដ៏ចាំបាច់ ដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានកំណត់ នោះគឺសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា។ រឿន ដារីន ជាយុវជនម្នាក់មកពីខេត្តកណ្តាលបានលើកឡើងថា *«ខ្ញុំនឹងបន្តធ្វើជាពលរដ្ឋល្អ សកម្ម និងមានទំនួលខុសត្រូវខ្ពស់ ប្រើឱ្យអស់នូវសមត្ថភាព និងសក្តានុពលរបស់ខ្ញុំ រួមសាមគ្គីជាមួយសហគមន៍ ក៏ដូចជារាជរដ្ឋាភិបាលដើម្បីអាចទទួលបានច្បាប់រៀបការស្មើភាពគ្នាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងពេលដ៏ឆាប់។ ខ្ញុំចង់ចំណាយពេលជាមួយមនុស្សដែលខ្ញុំស្រឡាញ់និងកាន់ដៃគ្នា ចូលរោងការ ដែលមានការទទួលស្គាល់ និងគាំទ្រពីសំណាក់ឪពុកម្តាយ និងចុះសំបុត្រអាពាហ៍ពិពាហ៍ស្របតាមច្បាប់ នៅចំពោះមុខអាជ្ញាធរ។»*



ប៉ាយន់ និងម៉ែអៀង រស់នៅខេត្តតាកែវបានមានប្រសាសន៍ថា *«យើងទាំងពីរនាក់បានតស៊ូជម្នះឧបសគ្គជាច្រើន រហូតមានការទទួលស្គាល់ពីឪពុកម្តាយ និងសាច់ញាតិ ហើយអាចរស់នៅជាមួយគ្នាជាង៤០ឆ្នាំមកដល់បច្ចុប្បន្ននេះ ដែលយើងនឹងកាន់ដៃគ្នារហូតដល់ជីវិតចុងក្រោយ។ ទោះបីយើងមានវ័យកាន់តែចាស់ក៏ពិតមែន ប៉ុន្តែយើងនៅតែមានក្តីសង្ឃឹមថា នឹងអាចបានចុះសំបុត្រអាពាហ៍ពាហ៍ជាមួយគ្នានាពេលខាងមុខ។»*



ទោះឆ្លងកាត់នូវគ្រាលំបាក ជូរចត់ កំសត់ និងរន្ធត់នៃសង្គ្រាមស៊ីវិលជាច្រើនរបប រាប់ទាំងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ក៏ដៃគូភេទដូចគ្នាបន្តចាប់ដៃ តស៊ូ ក្រាញនៀលរក្សានូវសេចក្តីស្រឡាញ់យ៉ាងស្មោះស្ម័គ្រចំពោះគ្នា។ រហូតកម្ពុជាទទួលបានសន្តិភាពពេញលេញ អាយុក៏កាន់តែជ្រេទៅមុខ សុខភាពក៏កាន់តែទន់ខ្សោយ ក៏ពួកគាត់មិនបោះបង់ចោលគ្នា ផ្ទុយទៅវិញពួកគាត់រឹតតែយកចិត្តទុកដាក់នៅក្បែរ មើលថែគ្នាយ៉ាងជាប់លាប់។ ដៃគូភេទដូចគ្នាខ្លះបានចាប់ដៃរួមរស់ជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំ ចន្លោះពី ៥០ឆ្នាំ ២០ឆ្នាំ ១០ឆ្នាំ និង៨ឆ្នាំ យ៉ាងតិចបំផុត។ រីឯយុវជនវ័យក្រោម៣០ឆ្នាំកំពុងតែទាក់ទង មើលចិត្តគ្នា និងសាងស្នេហ៍ដ៏ផ្អែមល្ហែម។ ដៃគូខ្លះបានសុំកូនសាច់ញាតិ ពីមន្ទីរពេទ្យ និងមណ្ឌលកុមារកំព្រាមកចិញ្ចឹមបីបាច់ ថែរក្សា រៀនសូត្រ ធំធាត់ ធ្វើការ មានជីវភាពប្រសើរ ហើយមានគូស្រករ កើតជាកូន ពូនជាចៅទៀតផង។ នេះហើយ គឺជាអត្ថន័យ និងគុណតម្លៃនៃសេចក្តីស្នេហា ជីវិតគូស្រករ និងគ្រួសារ មិនអាចកាត់ថ្លៃបានគួរឱ្យគោរពស្ញប់ស្ញែង។

នៅពេលចុះទៅមូលដ្ឋាន ជួបជជែក ស្តាប់រឿងរ៉ាវ និងបទពិសោធន៍របស់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ទាំងអ្នករស់នៅទីក្រុង ទីប្រជុំជន និងជនបទ នៅទូទាំងប្រទេសកម្ពុជា គឺមានភាពប្រហាក់ប្រហែលគ្នាចំពោះដំណើរជីវិត ការកសាងជីវភាព និងសុភមង្គលគូស្រករ គ្រួសារ និងបំណងប្រាថ្នា។ អាជ្ញាធរមួយចំនួនក៏បានធ្វើឯកសារអត្រានុកូលដ្ឋានទៅតាមស្ថានភាពគ្រួសារជាក់ស្តែង ដើម្បីអាចប្រើប្រាស់ជាប្រយោជន៍ និងជួយការពារតាមផ្លូវច្បាប់បានខ្លះៗ ជាពិសេសការទទួលបានសេវាកិច្ចគាំពារសង្គម។ ថ្វីត្បិតតែមិនទាន់អាចរៀបការតាមប្រពៃណី និងចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលកំណត់ដោយបទប្បញ្ញត្តិច្បាប់កម្ពុជាបាននៅឡើយ ក៏យើងសង្កេតឃើញថា មានដៃគូអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើនបានរៀបការតាមបែបប្រពៃណីក្នុងទម្រង់ផ្សេងៗដូចជា ពិធីឡើងគេហដ្ឋាន ខួបកំណើត និងភ្ជាប់ពាក្យជាដើម។ ពិធីនេះមានការចូលរួមជូនពរជ័យ ដឹងឮ និងអបអរពីឪពុកម្តាយ ក្រុមគ្រួសារ ក៏ដូចជាញាតិមិត្ត ដែលជាផ្នែកមួយនៃសេចក្តីសុខ និងភាពរីករាយ។ នេះគឺជាភស្តុតាងមួយទៀតដែលបញ្ជាក់ថា សង្គមខ្មែរមានភាពទូលាយក្នុងការទទួលយកដៃគូ និងគ្រួសារភេទដូចគ្នា ហើយអាចរស់នៅ ព្រមទាំងមានការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក ក្នុងភាពជាអ្នកជិតខាង សហគមន៍ ពលរដ្ឋ និងអាជ្ញាធរ។

ទោះជាមានការទទួលយក និងគាំទ្រច្រើនបែបនេះក្តី ក៏គូស្នេហ៍ភេទដូចគ្នាសុទ្ធសឹងតែមានបំណងប្រាថ្នាចូលរោងជ័យមង្គលតាមប្រពៃណី សំពះផ្ទឹមក្រាបក្បាលដល់កន្ទេលចំពោះមុខអ្នកមានគុណ ហើយចុះសំបុត្រអាពាហ៍ពិពាហ៍ស្របតាមច្បាប់ចំពោះមុខអាជ្ញាធរ ក្លាយជាសហព័ទ្ធ និងគ្រួសារដែលមានការទទួលស្គាល់ ហើយការពារពេញលេញ។ ប្រជាពលរដ្ឋខ្មែរទូទៅ ជាពិសេសអ្នកស្រឡាញ់ភេទផ្ទុយគ្នាបានដឹងច្បាស់ហើយទទួលស្គាល់ថា សំបុត្រអាពាហ៍ពិពាហ៍ពិតជា

មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីការពារសហព័ទ្ធ កូនចៅ និងគ្រួសារ។ ហេតុដូច្នេះ សេចក្តីប្រាថ្នារបស់ដៃគូភេទដូចគ្នាចំពោះតម្រូវការអាទិភាព នៃអាពាហ៍ពិពាហ៍ស្មើភាពគ្នាស្របតាមច្បាប់មិនមែនជារឿងចម្លែកឡើយ។

ក្រឡេកទៅមើលបទពិសោធនៃប្រទេសផ្សេងៗមាន**ប្រទេសកាន់តែច្រើនឡើងពីជុំវិញពិភពលោកដែលបានទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា**។ គួរកត់សម្គាល់ដែរថា គិតត្រឹមខែមករា ឆ្នាំ២០២៥ មានចំនួន៣៩(ដែលមានប្រទេសជាសមាជិកអង្គការសហប្រជាជាតិចំនួន៣៨ និងតៃវ៉ាន់) ដែលបានទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍គូស្រករភេទដូចគ្នារួចហើយ។ បទពិសោធពីប្រទេស ដែលបានទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នាបានបង្ហាញថា ការទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍ មានឥទ្ធិពលវិជ្ជមានក្នុងការពង្រឹងភាពជាគ្រួសារ កាត់បន្ថយការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា និងរួមចំណែកដល់**បរិយាបន្ន និងភាពសុខដុមក្នុងសង្គម**។ លើសពីនេះទៀត ភស្តុតាងជាសកល ពីប្រទេសទាំងនេះបង្ហាញថា **ការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ក៏នាំមកនូវផលវិជ្ជមាននៃផ្នែកសេដ្ឋកិច្ច** ក៏ដូចជា**រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព** ជាពិសេសក្នុងការជំរុញវិស័យទេសចរណ៍ វិស័យឧស្សាហកម្មសំខាន់ៗមួយចំនួន (ដូចជាក្នុងកម្មវិធីអាពាហ៍ពិពាហ៍ជាដើម) និងការទទួលស្គាល់សមភាពច្បាប់អាពាហ៍ពិពាហ៍ ក៏ជាគន្លឹះក្នុងការជំរុញបរិយាបន្នសង្គម ដោយរួមបញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា ដែលជាគន្លឹះក្នុងការរួមចំណែកទាក់ទាញការវិនិយោគ អាជីវកម្មអន្តរជាតិ និងជាតិ ជំរុញនូវផលិតភាពការងារខ្ពស់ និងការច្នៃ បង្កើតថ្មី ដែលជាធាតុសំខាន់ៗទាំងអស់ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសជាតិ។



ទាំងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ឳពុកម្តាយ ញាតិមិត្ត និងអ្នកគាំទ្ររបស់យើង នៅគ្រប់វិស័យ ទាំងសាធារណៈ ឯកជន ជាតិ តំបន់ និងអន្តរជាតិ បន្តប្រឹងប្រែងរួមគ្នាឥតឈប់ឈរ ដើម្បីឱ្យតម្រូវការអាទិភាពដែលបានកំណត់ដោយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាអាចសម្រេចបានដោយជោគជ័យ។ អាទិភាពនេះគឺជាផ្នែកដ៏សំខាន់នៃទិសដៅអភិវឌ្ឍប្រកបដោយចិរភាពដោយមិនទុកនរណាម្នាក់ចោល ជួយបង្ការ និងការពារពីភាពងាយរងគ្រោះ និងរងហានិភ័យរបស់គូស្រករ និងគ្រួសារ ដែលជាពលរដ្ឋខ្មែរទាំងអស់អាចរស់នៅក្នុងសង្គមកម្ពុជាប្រកបដោយការគោរព សមភាព បរិយាបន្ន ភាពសុខដុម និងសុខសន្តិភាពយ៉ាងពេញលេញ៕

##